


# សុវត្ថិភាពទីក្រុងឡុងប៊ិច

## គម្រោងទប់ស្កាត់អំពើហិង្សា

ទីក្រុង
ឡុងប៊ិច

# តើសុវត្ថិភាពទីក្រុងឡុងប៊ិចជាអ្វី?

ផែនការយុទ្ធសាស្ត្រដ៏ទូលំទូលាយសម្រាប់វិធានការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ សាលារៀន និងសហគមន៍។



**ចក្ខុវិស័យ៖** ប្រជាពលរដ្ឋទីក្រុងឡុងប៊ិច រស់នៅក្នុងគ្រួសារ និងសហគមន៍ប្រកបដោយសុវត្ថិភាព ចូលសាលារៀនប្រកបដោយសុវត្ថិភាព និងរួមចំណែកដល់សហគមន៍របស់ខ្លួន។

**គោលការណ៍ណែនាំ** អំឡុងខែឧសភា ឆ្នាំ 2014 ក្រុមប្រឹក្សាទីក្រុងឡុងប៊ិចបានអនុម័តលើផែនការទប់ស្កាត់អំពើហិង្សា ដែលហៅថា *សុវត្ថិភាពទីក្រុងឡុងប៊ិច (សុវត្ថិភាពទីក្រុងឡុងប៊ិច)*
ដើម្បីលើកឡើងពីរបៀបវារៈផ្នែកសុវត្ថិភាពឱ្យបានទូលំទូលាយ ក្នុងគោលបំណងកាត់បន្ថយអំពើហិង្សាគ្រប់ទម្រង់ ដែលរួមមានអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានកុមារ ការរំលោភបំពានមនុស្សចាស់ ឧក្រិដ្ឋកម្មស្អប់ខ្ពើម ការសម្លុតគំរាមកំហែង អំពើហិង្សាក្រុមក្មេងទំនើង និងឧក្រិដ្ឋកម្មហិង្សា។ *សុវត្ថិភាពទីក្រុងឡុងប៊ិច* ផ្សារភ្ជាប់ទំនាក់ទំនងគ្រប់វិន័យទាំងអស់ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រដ៏ទូលំទូលាយ ដោយបញ្ចូលគោលការណ៍ណែនាំខាងក្រោម ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ សាលារៀន និងសហគមន៍។

**តុល្យភាព** ថ្លឹងថ្លែងគណនេយ្យភាពរបស់បុគ្គល ដោយមានការជួយគ្នាទៅវិញទៅមក – រវាងអ្នកជិតខាងនិងអ្នកជិតខាង ឪពុកម្តាយនិងកូន រដ្ឋាភិបាលនិងប្រជាពលរដ្ឋ យុវវ័យនិងសហគមន៍ សហគមន៍/អង្គការសាសនានិងសមាជិក។

**សកម្មភាពសមូហភាព** ធ្វើការសម្រេចគោលដៅរួម ដោយប្រើធនធាន ចំណេះដឹង និងកិច្ចប្រឹងប្រែងរបស់ក្រុម។

**ប្រសិទ្ធភាព និងប្រសិទ្ធផល**
បង្កើនការសម្របសម្រួល និងការសហការ ដោយបង្កើតភាពជាដៃគូថ្មី និងរៀបចំធនធាន។

**ពង្រីកអ្វីដែលអាចទៅរួច** កំណត់ និងពង្រីកយុទ្ធសាស្ត្រ ដោយស្វែងរកធនធានបន្ថែម។

**ការរួមបញ្ចូល**
បង្កើនការរួមចំណែករបស់ប្រជាពលរដ្ឋ និងអ្នកជិតខាង និងកសាងទំនាក់ទំនងវិជ្ជមាន នៅគ្រប់លំដាប់ថ្នាក់។

**ភាពជាអ្នកដឹកនាំ** ជ្រើសរើសអ្នកដឹកនាំ និងអ្នកគាំទ្រ ចេញពីសាធារណជន ក្រុមហ៊ុនឯកជន អង្គការមិនស្វែងរកប្រាក់ចំណេញ អង្គការសាសនា និងសហគមន៍។

**បង្កើនឱកាស**
បង្កើនការចូលរួមរបស់ក្រុងជាមួយនឹងសមត្ថកិច្ចប្រចាំតំបន់ក្បែរខាង។

**ផ្តោតលើលទ្ធផល** ប្តេជ្ញាសម្រេចលទ្ធផលរួម និងសូចនាករសម្រាប់ទីក្រុងទាំងមូល និងបង្កើតវិធីសាស្ត្រតាមដានដំណើរការ។

# គោលដៅផ្សព្វផ្សាយស្តីពីសុវត្ថិភាពទីក្រុងឡុងប៊ិច

កំណត់ឫសគល់នៃអំពើហិង្សា និងកសាងទីក្រុងឡុងប៊ិចកាន់តែមានសុវត្ថិភាពត្រឹមឆ្នាំ 2020។



## គោលដៅ សុវត្ថិភាពនៅក្នុងគ្រួសារ សាលារៀន និងសហគមន៍

ដោយដឹងថា អំពើហិង្សាអាចកើតឡើងគ្រប់ពេលវេលានៅក្នុងជីវិតមនុស្ស និងក្នុងបរិបទផ្សេងៗ *សុវត្ថិភាពទីក្រុងឡុងប៊ិច* ត្រូវបានបង្កើតឡើងជាយុទ្ធសាស្ត្រ ដើម្បីបង្កើនសុវត្ថិភាពនៅក្នុងគ្រួសារ សាលារៀន និងសហគមន៍។ ជាជាងការទទួលស្គាល់អំពើហិង្សា *សុវត្ថិភាពទីក្រុងឡុងប៊ិច* ប្រើប្រាស់ធនធានជាច្រើនដែលមានស្រាប់របស់ទីក្រុង ដើម្បីកំណត់ឫសគល់នៃអំពើហិង្សា និងកសាងទីក្រុងឡុងប៊ិចដ៏កាន់តែមានសុវត្ថិភាពត្រឹមឆ្នាំ 2020។

### គោលដៅគ្រួសារ ៖

- បង្កើនលទ្ធភាពទទួលបានសេវាទប់ស្កាត់អំពើហិង្សា។
- កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ–ការរំលោភបំពានកុមារ អំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានមនុស្សចាស់។



### គោលដៅសាលារៀន៖

- បង្កើនអត្រារៀនចប់ថ្នាក់វិទ្យាល័យ។
- បង្កើនសុវត្ថិភាពខាងក្នុង និងជុំវិញសាលារៀន។

### គោលដៅសហគមន៍៖

- បង្កើនសុវត្ថិភាពប្រជាពលរដ្ឋក្នុងសហគមន៍។
- កាត់បន្ថយអត្រានិកម្មភាព។
- កាត់បន្ថយឧក្រិដ្ឋកម្មក្នុងផ្នែកទី 1។

## សូចនាករសំខាន់ៗ

- កាត់បន្ថយការបំពានធ្ងន់ធ្ងរ។
- កាត់បន្ថយករណីអំពើហិង្សាក្នុងគ្រួសារ។
- កាត់បន្ថយករណីរំលោភបំពានមនុស្សចាស់។
- កាត់បន្ថយមនុស្សឃាត។
- កាត់បន្ថយការចាប់រំលោភសេពសន្ថវៈ។
- កាត់បន្ថយការបាញ់កាំភ្លើង។
- កាត់បន្ថយចំនួនកុមារទទួលរងការរំលោភបំពាន និងការមិនអើពើ។
- កាត់បន្ថយចំនួនយុវវ័យជាប់ពន្ធនាគារ។
- កាត់បន្ថយអត្រានិកម្មភាព។
- កាត់បន្ថយឧក្រិដ្ឋកម្មហិង្សា។
- បង្កើនការយល់ដឹងរបស់សហគមន៍អំពីសុវត្ថិភាពប្រជាពលរដ្ឋ។

# តើសុវត្ថិភាពទីក្រុងឡុងប៊ិចពាក់ព័ន្ធនឹងបុគ្គលណាខ្លះ?

*សុវត្ថិភាពទីក្រុងឡុងប៊ិច* គឺជាផែនការដែលអាចផ្លាស់ប្តូរដោយភាគពាក់ព័ន្ធទាំងអស់






## កិច្ចប្រឹងប្រែងសហការ

*សុវត្ថិភាពទីក្រុងឡងប៊ិច* គឺជាផែនការដែលអាចផ្លាស់ប្តូរដោយភាគីពាក់ព័ន្ធទាំងអស់។ ផែនការនេះអាចធ្វើបច្ចុប្បន្នភាពទៅតាមពេលវេលា ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរ។ ក្នុងក្របខ័ណ្ឌនៃសកម្មភាពសមូហភាព កិច្ចសហការលើគ្រប់វិស័យ រួមមាន ធនធាន ចំណេះដឹង និងសកម្មភាព ត្រូវបានបញ្ចូលគ្នា និងផ្តោតទៅលើការជួយសម្រេចបាននូវគោលដៅរួមនៃការកាត់បន្ថយអំពើហិង្សា និងការបង្កើនសុវត្ថិភាព។

ជាផ្នែកមួយនៃការសម្រេចគោលដៅនានានៃ *សុវត្ថិភាពទីក្រុងឡងប៊ិច* ទីក្រុងបានអនុវត្តគំនិតផ្តួចផ្តើមជាច្រើន ដែលសំដៅកាត់បន្ថយអំពើហិង្សា ការបង្កើនការយល់ដឹង និងផ្តល់ធនធាន និងជំនួយ។ កិច្ចប្រឹងប្រែងទាំងនេះ រួមមាន *សុវត្ថិភាពគ្រួសារ សុវត្ថិភាពសាលារៀន និងសុវត្ថិភាពសហគមន៍ អ្នកថែទាំបង/ប្អូនប្រុសរបស់ខ្ញុំ អ្នកថែទាំបង/ប្អូនស្រីរបស់ខ្ញុំ* និង *គណៈកម្មាការទំនាក់ទំនងមនុស្ស*។




## ក្រុមសម្របសម្រួល

ក្រុមសម្របសម្រួល *សុវត្ថិភាពទីក្រុងឡងប៊ិច* មានតួនាទីណែនាំ ដើម្បីផ្តល់ការត្រួតពិនិត្យ ការណែនាំគោលនយោបាយ និងគណនេយ្យភាព។ ក្រុមនេះ រួមមាន ថ្នាក់ដឹកនាំកំពូលនៃទីភ្នាក់ងារសាធារណៈ គ្រឹះស្ថានអប់រំ មន្ត្រីសាលាក្រុង និងគ្រូពេទ្យនៅតាមមូលដ្ឋានជាដើម។ នៅពេលអនុវត្ត *សុវត្ថិភាពទីក្រុងឡងប៊ិច* ក្រុមនេះនឹងបន្តបញ្ចូលមតិត្រឡប់ និងអនុសាសន៍នានា ដើម្បីពង្រឹងផែនការនេះ។

## សុវត្ថិភាពគ្រួសារ សុវត្ថិភាពសាលារៀន សុវត្ថិភាពសហគមន៍

ដោយដឹងពីសារៈសំខាន់នៃការពង្រីកជំនួយសម្រាប់គ្រួសារនានាក្នុងទីក្រុងឡងប៊ិច ការផ្តួចផ្តើមគំនិតស្តីពី *សុវត្ថិភាពគ្រួសារ* ត្រូវបានធ្វើឡើងដើម្បីបំបែកវដ្តអន្តជំនាន់នៃអំពើហិង្សា និងបង្កើនកត្តាការពារតាមរយៈការប្រើប្រាស់កម្មវិធីផ្អែកលើភ័ស្តុតា និងលទ្ធផលដែលបានមកពីទិន្នន័យ។ *សុវត្ថិភាពទីក្រុងឡងប៊ិច* ផ្តល់អាទិភាពដល់ការយល់ដឹង និងការអប់រំ។ តាមរយៈការស្រាវជ្រាវដែលបង្ហាញថា ការជោគជ័យក្នុងការសិក្សាអាចទប់ស្កាត់អំពើហិង្សាយុវវ័យ *សុវត្ថិភាពសាលារៀន* មានគោលដៅបង្កើនអត្រារៀនចប់វិទ្យាល័យ និងបង្កើនសុវត្ថិភាពខាងក្នុង និងនៅជុំវិញសាលារៀន ដោយផ្តោតលើបញ្ហាមួយចំនួនដូចជា ការឈប់ឥតច្បាប់ និងការសម្លុតគំរាមកំហែង។ ជាចុងក្រោយ សុវត្ថិភាពសហគមន៍ ផ្តោតលើការបង្កើតបរិយាកាសដែលមានអ្នកជិតខាងផ្តល់ការយកចិត្តទុកដាក់និងការចូលរួម និងមានលទ្ធភាពទទួលបានការងារ ធនធានចាំបាច់ និងកន្លែងសុវត្ថិភាព ដែលនាំឱ្យសហគមន៍កាន់តែមានសុវត្ថិភាព។

# អំពាវនាវចាត់វិធានការ

លើកកម្ពស់ការបង្កើតគ្រួសារដែលមានភាពរឹងមាំ និងការគាំទ្រ អភិវឌ្ឍយុវជនវិជ្ជមាន និងគាំទ្រភាពជាអ្នកដឹកនាំសហគមន៍។

**កម្មវិធី និងគំនិតផ្តួចផ្តើមខាងក្រោមនេះ គឺពាក់ព័ន្ធនឹង *សុវត្ថិភាពទីក្រុងឡុងប៊ិច* និងជួយលើកកម្ពស់ការបង្កើតគ្រួសារដែលមានការគាំទ្រ អភិវឌ្ឍនយុវវ័យវិជ្ជមាន និងគាំទ្រភាពជាអ្នកដឹកនាំសហគមន៍។**



## អ្នកថែទាំបង/ប្អូនស្រីរបស់ខ្ញុំ

ទីក្រុងឡុងប៊ិច ទទួលបានជំនួយឥតសំណងសម្រាប់កម្មវិធីការកាត់បន្ថយ ការអន្តរាគមន៍ និងការទប់ស្កាត់ក្រុមក្មេងទំនើងនៅរដ្ឋកាលីហ្វ័រញ៉ា (CalGRIP) ក្នុងចំនួនទឹកប្រាក់ $1.5 លានដុល្លារ សម្រាប់រយ:ពេល 3 ឆ្នាំ។ កម្មវិធីដែលហៅថា *អ្នកថែទាំបង/ប្អូនស្រីរបស់ខ្ញុំ* នេះ សំដៅទប់ស្កាត់ការក្លាយខ្លួនជាសមាជិកក្រុមក្មេងទំនើង និងការក្លាយជាជនរងគ្រោះដោយក្រុមក្មេងទំនើង ក្នុងចំណោមស្រ្តីដែលស្ថិតក្នុងគ្រោះថ្នាក់។ គម្រោងនេះនឹងរួមមាន យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីការជួញដូរមនុស្ស ការគ្រប់គ្រងករណី ការព្យាបាលសុខភាពផ្លូវចិត្ត ការផ្តល់ជំនួយលំនៅឋាន និងការណែនាំ។

## អ្នកថែទាំបង/ប្អូនប្រុសរបស់ខ្ញុំ

អំឡុងខែមករា ឆ្នាំ 2015 ក្រុមប្រឹក្សាទីក្រុងឡុងប៊ិច បានអនុម័តសេចក្តីសម្រេចគាំទ្រគំនិតផ្តួចផ្តើមរបស់ប្រធានាធិបតីអូបាម៉ា ក្នុងការបង្កើតសហគមន៍ អ្នកថែទាំបង/ប្អូនប្រុសរបស់ខ្ញុំ (MBK) ដើម្បីជួយលុបបំបាត់គម្លាតឱកាស ដែលយុវវ័យកំពុងប្រឈម និងធានាថា យុវវ័យទាំងអស់អាចបញ្ចេញសក្តានុពលរបស់ខ្លួនយ៉ាងពេញលេញ។ ការអំពាវនាវឱ្យចាត់វិធានការនេះ លើកទឹកចិត្តសហគមន៍ឱ្យអនុវត្តយុទ្ធសាស្រ្តនានាដើម្បីធ្វើឱ្យអនាគតរបស់យុវវ័យប្រសើរឡើង ដោយមិនប្រកាន់ថា ពួកគេជានរណា ពួកគេមកពីណា ឬ ពួកគេកើតក្នុងកាលៈទេសៈណានោះទេ។

## ក្រសួងយុត្តិធម៌ជាតិសហរដ្ឋអាមេរិក វេទិកាស្តីពីការទប់ស្កាត់អំពើហិង្សាយុវវ័យ

ទីក្រុងឡុងប៊ិចត្រូវបានជ្រើសរើសឱ្យស្ថិតក្នុងចំណោមក្រុងចំនួន 15 របស់សហរដ្ឋអាមេរិក ដើម្បីចូលរួមវេទិកាជាតិស្តីពីការទប់ស្កាត់អំពើហិង្សាយុវវ័យ និងទទួលបានជំនួយឥតសំណងសម្រាប់ការទប់ស្កាត់អំពើហិង្សាយុវវ័យ និងក្មេងទំនើង។ ការជ្រើសរើសនេះ ផ្តល់នូវជំនួយបច្ចេកទេសជំនួសឱ្យក្រសួងយុត្តិធម៌ (DOJ) សហរដ្ឋអាមេរិក និងអនុញ្ញាតឱ្យទីក្រុងដាក់ពាក្យស្នើសុំជំនួយឥតសំណងរបស់សហព័ន្ធបន្ថែមសម្រាប់ការអនុវត្ត សុវត្ថិភាពទីក្រុងឡុងប៊ិច។

## គណៈកម្មការទំនាក់ទំនងមនុស្ស

គណៈកម្មការទំនាក់ទំនងមនុស្ស មានគោលបំណងផ្តល់វេទិកាមួយ ដើម្បីឱ្យទំនាក់ទំនងមនុស្សកាន់តែប្រសើរ និងលើកកម្ពស់ឆន្ទៈរបស់មនុស្ស ក្រុមមនុស្ស និងស្ថាប័ននានា ដើម្បីរក្សាបាននូវមោទនភាព និងសន្តិភាពរបស់ប្រជាពលរដ្ឋ និងបង្កើន ការយោគយល់ និងការគោរពគ្នាទៅវិញទៅមករវាងប្រជាពលរដ្ឋទាំងអស់នៅក្នុងសហគមន៍។

សម្រាប់ព័ត៌មានបន្ថែមស្តីពី *សុវត្ថិភាពទីក្រុងឡុងប៊ិច*
សូមចូលទៅកាន់គេហទំព័រ www.lbvpp.com។

ទីក្រុង
ឡុងប៊ិច


**សេវាអភិវឌ្ឍន៍ទីក្រុងឡុងប៊ិច**

333 W. Ocean Blvd., 3rd Floor

Long Beach, CA 90802


សូមចូលទៅកាន់គេហទំព័រ www.lbds.info

facebook.com/LongBeachDevelopmentServices

@LongBeachDS

ព័ត៌មាននេះអាចរកបានជាទម្រង់ផ្សេងទៀត តាមការស្នើសុំទៅកាន់ (562) 570-3807។

សម្រាប់កំណែអេឡិចត្រូនិកនៃខិត្តប័ណ្ណនេះ សូមចូលទៅកាន់គេហទំព័រ www.lbds.info។